ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

# សេចក្តីជូនដំណឹងជាសាធារណៈ

ក្រសួងយុត្តិធម៌សូមជម្រាបជូនដំណឹងជាសាធារណៈដល់បុគ្គល ឬអង្គភាពក្រៅពីបុគ្គលរាយការណ៍ មេត្តាជ្រាបថា ក្រសួងយុត្តិធម៌ បានទទួលដីកាសម្រេចបង្កកទ្រព្យសម្បត្តិលេខ ១១ "ហ" ដ.ប.ទ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២០ និងដីកាសម្រេចបង្កកទ្រព្យសម្បត្តិលេខ ១២ "ង១" ដ.ប.ទ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលដីកាសម្រេចទាំង០២នេះ គឺធ្វើឡើងស្របតាមសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិលេខ ១៧១៨(២០០៦), ១៧៣៧(២០០៦), ១៨៧៤(២០០៩), ២០៨៧(២០១៣), ២០៩៤(២០១៣), ២២៣១(២០១៥), ២២៧០(២០១៦), ២៣២១(២០១៦), ២៣៧១(២០១៧), ២៣៧៥(២០១៧) និង២៣៩៧(២០១៧)។ ដីកាសម្រេចទាំង០២នេះ មានផ្សព្វផ្សាយក្នុងគេហទំព័រផ្លូវការរបស់ក្រសួងយុត្តិធម៌កាលពីថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០។ ផ្អែកតាមច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦២០/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ និងអនុក្រឹត្យលេខ ១៦១ អនក្រ.បក ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីបែបបទ និងនីតិវិធីក្នុងការអនុវត្តច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ក្រសួងយុត្តិធម៌សូមជម្រាបជូនដំណឹងជាសាធារណៈដល់បុគ្គល ឬអង្គភាពដែលកំពុងកាន់កាប់ទ្រព្យសម្បត្តិបង្កកតាមដីកាសម្រេចបង្កកទ្រព្យសម្បត្តិទាំង០២ ខាងលើ ត្រូវបង្កកទ្រព្យសម្បត្តិទាំងនោះដោយគ្មានបង្អង់ ហើយត្រូវរាយការណ៍ក្នុងរយៈពេលមិនលើសពី០៣ថ្ងៃ អំពីការបង្កកទ្រព្យសម្បត្តិ និងរាល់ការប៉ុនប៉ងធ្វើប្រតិបត្តិការលើទ្រព្យសម្បត្តិដែលបានបង្កកនោះមកក្រសួងយុត្តិធម៌។ ចំពោះបុគ្គលរាយការណ៍ដែលជាប់កាតព្វកិច្ចតាមមាត្រា១២ (កាតព្វកិច្ចរាយការណ៍របស់បុគ្គលរាយការណ៍) នៃច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ត្រូវរាយការណ៍ទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដែលនឹងត្រូវចាត់វិធានការដោយឡែកតាមមាត្រា១២ (កាតព្វកិច្ចរាយការណ៍របស់បុគ្គលរាយការណ៍) នៃច្បាប់ដដែលនេះ។

បុគ្គល ឬអង្គភាពដែលកំពុងកាន់កាប់ទ្រព្យសម្បត្តិបង្កកដែលមិនអនុវត្តតាមដីកាសម្រេចបង្កកទ្រព្យសម្បត្តិលេខ ១១ "ហ" ដ.ប.ទ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២០ និងដីកាសម្រេចបង្កកទ្រព្យសម្បត្តិលេខ ១២ "ង១" ដ.ប.ទ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

សេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ និងដីកាសម្រេចបង្កកទ្រព្យសម្បត្តិ របស់សាលាដំបូងរាជធានីភ្នំពេញទាំង០២ ខាងលើ អាចរកបានតាមរយៈគេហទំព័រផ្លូវការរបស់ក្រសួងយុត្តិធម៌។

ថ្ងៃព្រហស្បតិ៍ ១២ រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០

សម្រាប់ព័ត៌មានបន្ថែម
សូមទាក់ទងឈ្មោះ គា ម៉ីម៉ី
លេខទូរស័ព្ទ(៨៥៥) ១២ ៧០២ ០២៩